ជាដៃគូអាជីវកម្មដ៏ល្អរបស់លោកអ្នក

# របាយការណ៍
# ប្រចាំឆ្នាំ២០២១

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី

BNKC (Cambodia) Microfinance Institution Plc.

# របាយការណ៍

# ប្រចាំឆ្នាំ២០២១


11:03
ត្រឡប់
កម្ចីខ្នាតមធ្យម
មានជម្រើសសម្រាប់ប្រាក់រៀល និងប្រាក់ដុល្លារ និងអត្រាការប្រាក់សមរម្យ ដែលគណនាផ្អែកលើចំនួនសមតុល្យកម្ចីនៅសល់ រយៈពេលខ្ចីមានភាពបត់បែននិងការបង់សងផ្អែកលើតម្រូវការអតិថិជន។ មានភាពងាយស្រួលក្នុងការស្នើសុំកម្ចី និងអាចបង់សងតាមការិយាល័យ ប៊ីអេនខេស៊ី នៅជិតទីតាំងលោកអ្នកបំផុត។
ការណែនាំកម្ចី
ទំហំកម្ចី
ចាប់ពី ១៥.០០០ ឡើងទៅ
អត្រាការប្រាក់
០.៩% ទៅ ១.៥.៤% ក្នុងមួយខែ (អាស្រ័យលើការចរចា)
រយៈពេលខ្ចី
វិធីសាស្ត្រទូទាត់
ស្នើសុំឥឡូវ




# មាតិកា


**អំពីក្រុមហ៊ុន**

តួលេខសំខាន់ៗ 06
ព័ត៌មានគ្រឹះស្ថាន 07
ភាគទុនិក 08
ក្រុមប្រឹក្សាភិបាល 09
ទស្សនៈវិស័យ | បេសកកម្ម | គោលដៅយុទ្ធសាស្ត្រ 10
ចំណាប់អារម្មណ៍របស់អគ្គនាយកប្រតិបត្តិ 11

**ប្រតិបត្តិការរបស់យើង**

តំបន់ប្រតិបត្តិការ 12
ផលិតផល និងសេវាកម្ម 16

**ក្រុមការងាររបស់យើង**

រចនាសម្ព័ន្ធគ្រឹះស្ថាន 18
គណៈគ្រប់គ្រងកំពូល 19
គណៈគ្រប់គ្រង 20
ការអភិវឌ្ឍសមត្ថភាពបុគ្គលិក 25
សុវត្ថិភាពសុខភាពនៅកន្លែងការងារក្នុងអំឡុងពេលកូវីដ១៩ 30
ទំនួលខុសត្រូវផ្នែកសង្គម 32

**របាយការណ៍សវនកម្មឯករាជ្យ**

របាយការណ៍សវនកម្មឯករាជ្យ 33

# តួលេខសំខាន់ៗ

## សាខា




## ប្រាក់ចំណេញសុទ្ធ

(ពាន់រៀល)




## អតិថិជន




## សមតុល្យផលប័ត្រឥណទានសរុប

(ពាន់រៀល)




## បុគ្គលិក




២០១៩ ២០២០ ២០២១

# ព័ត៌មានគ្រឹះស្ថាន




ការិយាល័យកណ្តាលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (អាគារប៊ីវ៉េ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ)

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេនខេស៊ី** (ខេមបូឌា) ភីអិលស៊ី ដែលមានឈ្មោះដើមថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ខេប៊ីអេសស៊ី (ខេមបូឌា) ភីអិលស៊ី ជាសាជីវកម្មទទួលខុសត្រូវមានកម្រិតដែលបានទទួលអាជ្ញាប័ណ្ណពីធនាគាជាតិនៃកម្ពុជានៅថ្ងៃទី០៧ ខែឧសភាឆ្នាំ២០១៥។ គ្រឹះស្ថានទទួលបានការវិនិយោគ ១០០% ពីក្រុមហ៊ុនមេ BNK Capital Co,. Ltd. មានមូលដ្ឋាននៅ ទីក្រុងប៊ូសាន នៃសាធារណរដ្ឋកូរ៉េ នូវដើមទុនចំនួន ១៥លានដុល្លារសហរដ្ឋអាមេរិក។ គោលបំណងចំបងរបស់គ្រឹះស្ថាន គឺផ្តល់សេវាហិរញ្ញវត្ថុដ៏ល្អបំផុតជូនប្រជាជនកម្ពុជាប្រកបដោយទំនួលខុសត្រូវ និងតម្លាភាព ព្រមទាំងចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ លើសពីនេះទៅទៀត ប៊ីអេនខេស៊ី កំពុងតែបានផ្តល់នូវឱកាសការងារជូនដល់និយោជិតដែលមានបំណងចង់អភិវឌ្ឍន៍សមត្ថភាព និងជំនាញឲ្យចូលរួមបម្រើការងារក្នុងគ្រឹះស្ថានដើម្បីភាពរីកចម្រើនទៅថ្ងៃអនាគត។

# ភាគទុនិក

## BNK Capital

ក្រុមហ៊ុន BNK Capital ដែលមានឈ្មោះដើមក្រុមហ៊ុន BS Capital បានប្តូរឈ្មោះទៅជា BNK Capital នៅខែមីនា ឆ្នាំ ២០១៥។ ក្រុមហ៊ុននេះបានបង្កើតឡើងនៅឆ្នាំ២០១០ ដែលមានទីស្នាក់ការនៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ។ BNK Capital គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៃ BNK Financial ដែលផ្តោតលើអតិថិជនដែលមានប្រាក់ចំណូលទាប និងមធ្យម។ BNK Capital **គឺជាក្រុមហ៊ុនឯកទេសផ្នែកឥណទាន** មានប្រតិបត្តិការនៅប្រទេសកូរ៉េខាងត្បូងដែលផ្តោតសំខាន់ ក្នុងការគាំទ្រដល់ការផ្តល់ប្រាក់កម្ចីសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនប្រាក់កម្ចីទិញផ្ទះ ផ្តល់ហិរញ្ញប្បទានភតិសន្យា ផ្តល់ហិរញ្ញប្បទានរំលោះ ផ្តល់ហិរញ្ញប្បទានដល់ក្រុមហ៊ុនសាជីវកម្ម និងផ្តល់សេវាទូទាត់វិក្កយបត្រតាមរោងចក្រនានាជាដើម។



ការវិនិយោគ



ដើមទុនដែលបានចុះបញ្ជី


ការិយាល័យកណ្ដាល BNK Capital Co., Ltd


បុគ្គលិកឆ្នើមមកពីសាជីវកម្មក្រៅប្រទេសបានចូលរួម 'We Are BNK!' ជាកម្មវិធីដែលរៀបចំដោយ BNKC Capital នៅសាធារណៈរដ្ឋកូរ៉េ។

# ក្រុមប្រឹក្សាភិបាល



លោក LEE DOOHO
ប្រធានក្រុមប្រឹក្សាភិបាល



លោក KIM SOONJO
សមាជិកក្រុមប្រឹក្សាភិបាល



លោក KIM SUNGHWA
សមាជិកក្រុមប្រឹក្សាភិបាល



លោក KIM JONGCHUL
សមាជិកក្រុមប្រឹក្សាភិបាល



លោក អ៊ីវ ប៉ូលី
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

# ទស្សនៈវិស័យ | បេសកកម្ម | គោលដៅយុទ្ធសាស្ត្រ



ជាដៃគូអាជីវកម្មដ៏ល្អរបស់លោកអ្នក

## ទស្សនៈវិស័យ

ផ្តល់នូវសេវាកម្មផ្នែកហិរញ្ញវត្ថុល្អបំផុតជូនទៅ
ប្រជាជនកម្ពុជាដើម្បីការរីកចម្រើនប្រកបដោយនិរន្តរភាព

## បេសកកម្ម

លើកស្ទួយកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា
ពង្រឹងតម្លៃរបស់អតិថិជន បុគ្គលិក ម្ចាស់ភាគហ៊ុន និងសង្គមជាតិ

## គោលដៅយុទ្ធសាស្ត្រ

បង្កើតផលិតផលផ្សេងៗ
និងពង្រីកតំបន់ទីផ្សារ

បង្កើនសុចរិតភាព
និងប្រាក់ចំណេញ

បង្កើនគុណភាពនៃទ្រព្យ
សកម្មដោយពង្រឹង
ការគ្រប់គ្រងហានិភ័យ

# ចំណាប់អារម្មណ៍របស់អគ្គនាយកប្រតិបត្តិ



**លោក KIM Soonjo**

**អគ្គនាយកប្រតិបត្តិ**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី

ជម្រាបសួរ អតិថិជនជាទីគោរព! ខ្ញុំបាទ KIM Soonjo ជាអគ្គនាយកប្រតិបត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី ។

ខ្ញុំអាចនិយាយបានថាឆ្នាំ២០២១ជាឆ្នាំដែលមានឧបសគ្គជាច្រើនជាងឆ្នាំណាៗទាំងអស់ដែលបានជួបប្រទះ។ ចាប់តាំងពីខែមេសាមក បញ្ហាជាច្រើនបានកើតឡើងដោយសារជំងឺរាតត្បាតកូវីដ-១៩ ដែលបានរីករាលដាលពេញពីទីក្រុងភ្នំពេញ។ រោងចក្រមួយចំនួន ត្រូវបានបិទជាបណ្តោះអាសន្ន ហើយមានគ្រោះធម្មជាតិដូចជាទឹកជំនន់ បានកើតឡើង ជាបន្តបន្ទាប់។ ពេលវេលាដ៏លំបាកនេះជាការលំបាកសកលដែលបានជួបប្រទះ។

ទោះបីជាយ៉ាងណាក្តីគណៈគ្រប់គ្រងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី (ដែលហៅកាត់ថា «ប៊ីអេនខេស៊ី») បានខិតខំប្រឹងប្រែងឥតឈប់ឈរដើម្បីការពារការឆ្លងមេរោគកូវីដ-១៩ ទាំងក្នុងនិងទាំងក្រៅគ្រឹះស្ថាន។ ពោលគឺយើងបានផ្តល់ការគាំទ្រជាអតិបរមានៅកម្រិតគ្រឹះស្ថាន ដើម្បីអោយបុគ្គលិកអាចធ្វើសកម្មភាពប្រតិបត្តិការដោយសុវត្ថិភាព ហើយអតិថិជនអាចចូលមកកាន់សាខានីមួយៗ ដោយមានទំនុកចិត្ត និងសុវត្ថិភាព។

ប៊ីអេនខេស៊ី បន្តឈានទៅមុខក្នុងគោលដៅរីកចម្រើនជាមួយអតិថិជន នៅក្រោមពាក្យស្លោកមួយឃ្លា «ដៃគូអាជីវកម្មល្អបំផុតរបស់អ្នក!» ដែលជាពាក្យសន្យារបស់គ្រឹះស្ថាន ជាមួយនឹងអតិថិជន។ ដូច្នេះហើយ នៅខែមិថុនា ឆ្នាំ២០២១ យើងបានដាក់ឱ្យដំណើរការកម្មវិធីទូរស័ព្ទដៃ « BNKC Mobile App » ជាផ្លូវការដែលជាសេវាកម្មហិរញ្ញវត្ថុដែលអាចប្រើប្រាស់បាននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាជូនដល់អតិថិជន។

មានអតិថិជនចំនួន ៨,៨០៤នាក់ ដែលបន្តបង្ហាញភាពទុកចិត្ត និងគាំទ្រចំពោះគ្រឹះស្ថានយើង! នៅចុងឆ្នាំ២០២១ ប៊ីអេនខេស៊ី សម្រេចបានចំណូលសុទ្ធចំនួន ៩៨៣.៥ លានរៀល កើនឡើង ២៩.៩% បើប្រៀបធៀបនឹងឆ្នាំមុន និងសម្រេចបានសមតុល្យ ២៨៣,៩៤៤ លានរៀល កើនឡើងប្រមាណ ៥៧% បើប្រៀបធៀបនឹងឆ្នាំមុន។

អតិថិជនជាទីគោរព!
រួមទៅការរីកចម្រើនជាមួយអតិថិជន គ្រឹះស្ថានបានខិតខំព្យាយាមពង្រឹងផលិតផល និងសេវាកម្មទាំងអស់ឲ្យមានគុណភាព ភាពងាយស្រួល និងឆាប់រហ័ស តាមរយៈការបណ្តុះបណ្តាលដល់បុគ្គលិកផ្នែកប្រតិបត្តិការលើវិន័យ ក្រមសីលធម៌ និងធ្វើការអភិវឌ្ឍន៍ផ្នែកព័ត៌មានវិទ្យា។ លើសពីនេះទៅទៀត គ្រឹះស្ថានបាននឹងកំពុងបំពេញ តួនាទីក្នុងការចូលរួមកិច្ចការសង្គមជាច្រើន។ គ្រឹះស្ថានបានអនុវត្ត និងប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំទាំងអស់របស់ធនាគារជាតិនៃកម្ពុជា តម្លាភាព វិជ្ជាជីវៈរបស់និយោជិក ទំនួលខុសត្រូវ និង សីលធម៌គ្រប់គ្រង ហើយព្យាយាមក្លាយខ្លួនជាគ្រឹះស្ថានហិរញ្ញវត្ថុមួយដែលយកភាពស្មោះត្រង់ជាមូលដ្ឋាន។

ជាថ្មីម្តងទៀត គ្រឹះស្ថាន ប៊ីអេនខេស៊ី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអតិថិជនទាំងអស់ ដែលបានគាំទ្រក្នុងការប្រើប្រាស់សេវាប្រាក់កម្ចីរបស់គ្រឹះស្ថាន សូមជូនពរដល់លោក លោកស្រី អ្នកនាងកញ្ញា និងក្រុមគ្រួសារប្រកបដោយសេចក្តីសុខ សុខភាពល្អ សុភមង្គល ជោគជ័យគ្រប់ភារៈកិច្ចការងារ និងសម្រេចគ្រប់បំណងប្រាថ្នា។

សូមអរគុណ!

**លោក KIM Soonjo**
អគ្គនាយកប្រតិបត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី

# តំបន់ប្រតិបត្តិការ

ដោយសារការខំប្រឹងប្រែងកន្លងមកនេះដំណើរការអាជីកម្មរបស់គ្រឹះស្ថាន
មានការរីកចម្រើនយ៉ាងរលូនគួរអោយកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ។
គ្រឹះស្ថាននឹងបន្តពង្រីកអាជីវកម្មរបស់ខ្លួនជាបន្តបន្ទាប់នៅឆ្នាំខាងមុខ។




**៦,៩លាន**
**ដុល្លារអាមេរិក**
សមតុល្យផលប័ត្រ
ឥណទានសរុប

**៨,៨០៤**
ចំនួនអតិថិជន

**២,៥៦០ ភូមិ**
**៦៣១ ឃុំ**
**៩ ក្រុង**
តំបន់ប្រតិបត្តិការ

**ពណ៌មានលម្អិតអំពីតំបន់ប្រតិបត្តិការ ( ១៥ សាខា )**

- រាជធានីភ្នំពេញ (សាខាចំនួន ០១ ទីស្នាក់ការកណ្តាល)
- ខេត្តកណ្តាល (សាខាចំនួន ០៣ ស្រុកអង្គស្នួល ស្រុកកណ្តាលស្ទឹង ស្រុកខ្សាច់កណ្តាល)
- ខេត្តកំពង់ស្ពឺ (សាខាចំនួន ០៣ ក្រុងច្បារមន ស្រុកឧត្តុង្គ ស្រុកបរសេដ្ឋ)
- ខេត្តកំពង់ចាម (សាខាចំនួន ០១ ស្រុកជើងព្រៃ)
- ខេត្តតាកែវ (សាខាចំនួន ០១ ស្រុកត្រាំកក់)
- ខេត្តកំពត (សាខាចំនួន ០១ ស្រុកឈូក ក្រុងកំពត)
- ខេត្តសៀមរាប (សាខាចំនួន ០១ ក្រុងសៀមរាប)
- ខេត្តបាត់ដំបង (សាខាចំនួន ០១ ក្រុងបាត់ដំបង)
- ខេត្តបន្ទាយមានជ័យ (សាខាចំនួន ០២ ក្រុងសិរីសោភ័ណ ក្រុងប៉ោយប៉ែត)


ជើងព្រៃ
ខ្សាច់កណ្ដាល
ឧត្ដុង្គ
អង្គស្នួល
ភ្នំពេញ
ច្បារមន
កណ្ដាលស្ទឹង
បរសេដ្ឋ
ត្រាំកក់
ឈូក
កំពត

# សាខា




**ទីស្នាក់ការកណ្តាល**
អាគារប៊ីរ៉េ មហាវិថីព្រះនរោត្តម
សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (៨៥៥) ២៣ ២១៣ ៩០០




**សាខាក្រុងច្បារមន**
ភូមិបុរីកម្មករ សង្កាត់រកាធំ
ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ (៨៥៥) ២៥ ២១០ ២២៩




**សាខាស្រុកអង្គស្នួល**
ភូមិចុងបង្គោល ឃុំបែកចាន
ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ៖ (៨៥៥) ២៣ ៧២៩ ៧១១




**សាខាស្រុកឧដុង្គ**
ភូមិឧត្តុង្គ ឃុំវាំងចាស់
ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ (៨៥៥) ២៥ ២១៨ ២៨២




**សាខាស្រុកកណ្តាលស្ទឹង**
ភូមិសៀមរាប ឃុំសៀមរាប
ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល
ទូរស័ព្ទ៖ (៨៥៥) ២៤ ៩០០ ១៣៥




**សាខាស្រុកបរសេដ្ឋ**
ភូមិផ្សារស្លាបលែង ឃុំស្វាយរំពារ
ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ (៨៥៥) ២៥ ៩០០ ១១០




**សាខាស្រុកខ្សាច់កណ្តាល**
ភូមិព្រែកតាមាក់ ឃុំព្រែកតាមាក់
ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
ទូរស័ព្ទ៖ (៨៥៥) ២៤ ៩០០ ១៣១




**សាខាស្រុកជើងព្រៃ**
ភូមិប៉ាណា ឃុំសូទិព្វ
ស្រុកជើងព្រៃ ខេត្តកំពង់ចាម
ទូរស័ព្ទ៖ (៨៥៥) ៤២ ៩០០ ១១០




**សាខាស្រុកត្រាំកក់**

ភូមិព្រៃរំដេង ឃុំអង្គតាសោម
ស្រុកត្រាំកក់ ខេត្តតាកែវ
ទូរស័ព្ទ៖ (៨៥៥) ៣២ ២១៥ ២១៥




**សាខាក្រុងបាត់ដំបង**

ភូមិកម្មករ សង្កាត់ស្វាយប៉ោ
ក្រុងបាត់ដំបង ខេត្តបាត់ដំបង
ទូរស័ព្ទ៖ (៨៥៥)៥៣ ៩៥២ ៩៥២




**សាខាស្រុកឈូក**

ភូមិឈើទាល ឃុំឈូក
ស្រុកឈូក ខេត្តកំពត
ទូរស័ព្ទ៖ (៨៥៥) ៣៣ ៩០០ ១៣៥




**សាខាក្រុងសេរីសោភ័ណ**

ភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរី
សោភ័ណ ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ៖ (៨៥៥) ៥៤ ៩០០ ១១២




**សាខាក្រុងកំពត**

ភូមិស្វាយធំ សង្កាត់ក្រាំងអំពិល
ក្រុងកំពត ខេត្តកំពត
ទូរស័ព្ទ៖ (៨៥៥) ៣៣ ៩០០ ១១០




**សាខាក្រុងប៉ោយប៉ែត**

ភូមិប៉ាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត
ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ៖ (៨៥៥) ៥៤ ៩០០ ១១០




**សាខាក្រុងសៀមរាប**

ភូមិទ្រាំង សង្កាត់ស្លក្រាម
ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ៖ (៨៥៥) ៦៣ ៧៥៦ ៧២២

# ផលិតផល និងសេវាកម្ម



**ឥណទានសម្រាប់អាជីវកម្មទូទៅ៖** ជាប្រភេទឥណទានឯកត្តជន ឬជាក្រុមដែលផ្តល់សម្រាប់គ្រប់ប្រជាជនកម្ពុជាដែលមានបំណងចង់បង្កើតអាជីវកម្ម និងពង្រីកអាជីវកម្ម ដើម្បីសម្រួលដល់ប្រភពចំណូលរបស់ពួកគាត់។ កម្ចីអាច ផ្តល់បានរហូតដល់ ៥០,០០០ ដុល្លារ ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៧២ ខែ។

**ឥណទានកសិកម្ម៖** ជាប្រភេទឥណទានឯកត្តជន ឬក្រុមដែលផ្តល់សម្រាប់គ្រប់ប្រជាជនកម្ពុជា ដែលមានបំណងចង់បង្កើតនូវមុខរបរផ្សេងៗដែលទាក់ទងនឹងវិស័យកសិកម្មដាំដុះនាៗ ដែលអាចជួយបង្កើននូវចំណូលរបស់ពួក គាត់។ កម្ចីអាចផ្តល់បាន រហូលដល់ ៣០,០០០ ដុល្លារ ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៤៨ខែ។

**ឥណទានគេហដ្ឋាន៖** ជាប្រភេទឥណទានឯកត្តជនដែលផ្តល់សម្រាប់គ្រប់ប្រជាជនកម្ពុជា ដែលមាន បំណងចង់ធ្វើការទិញនូវអចលនទ្រព្យ ដូចជា ដី សម្រាប់សាងសង់ផ្ទះ ទិញនូវគេហដ្ឋានថ្មី ឬសម្រាប់ទិញនូវ Condo /Apartment។ កម្ចីអាចផ្តល់បានរហូតដល់ ៥០,០០០ ដុល្លារ ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៧២ខែ។

**ឥណទានសម្រាប់កែលម្អគេហដ្ឋាន៖** ជាប្រភេទឥណទានឯកត្តជនដែលផ្តល់សម្រាប់គ្រប់ប្រជាជនកម្ពុជាដែលមានបំណងចង់ធ្វើការជួសជុល ឬរៀបចំកែលម្អនូវគេហដ្ឋានរបស់ពួកគាត់អោយបានល្អប្រសើរ។ កម្ចីអាចផ្តល់បាន រហូតដល់ ១៥,០០០ ដុល្លារ ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៧២ខែ។

**ឥណទានរថយន្ត៖** ជាប្រភេទឥណទានឯកត្តជនដែលផ្តល់សម្រាប់គ្រប់ប្រជាជនកម្ពុជាដែលមានបំណងចង់ធ្វើការទិញនូវរថយន្តសម្រាប់ប្រើប្រាស់ក្នុងក្រុមគ្រួសាររបស់ពួកគាត់ និងមិនមែនសម្រាប់ធ្វើអាជីវកម្ម។ កម្ចីអាចផ្តល់បានរហូតដល់ ៣០,០០០ ដុល្លារ ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៧២ខែ។

**ឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន៖** ជាប្រភេទឥណទានឯកត្តជនដែលផ្តល់សម្រាប់គ្រប់ប្រជាជនកម្ពុជាដែលមានបំណងចង់ធ្វើការទិញនូវឧបករណ៍ផ្សេងៗ សម្រាប់បម្រើក្នុងក្រុមគ្រួសារ ឬរបស់ផ្ទាល់ខ្លួនពួកគាត់។ កម្ចីអាច ផ្តល់បានរហូលដល់ ១៥,០០០ ដុល្លារ ឬសមមូលជាប្រាក់រៀលខ្មែរ និងរយៈពេលកម្ចីរហូតដល់ ៧២ ខែ។

**ឥណទានទិញសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ៖** ជាប្រភេទឥណទានឯកត្តជនដែលមិនត្រូវការទ្រព្យសម្រាប់ធានាបំណុលហើយផ្តល់សម្រាប់គ្រប់ប្រជាជនកម្ពុជាដែលមានបំណងចង់ធ្វើការទិញនូវឧបករណ៍អេឡិចត្រូនិចផ្សេងៗ ដូចជាទូរស័ព្ទដៃ កុំព្យូទ័រយួរដៃ -ល-។ កម្ចីអាចផ្តល់បានរហូលដល់ ១០,០០០ ដុល្លារ ឬសមមូលជាប្រាក់រៀលខ្មែរ និង រយៈពេលកម្ចីរហូតដល់ ៣៦ខែ។




## សេវាកម្ម UNTACT កម្មវិធីទូរស័ព្ទដៃ « BNKC Mobile App »

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី ចាប់ផ្តើមបើកដំណើរការណ៍កម្មវិធីទូរស័ព្ទដៃ ដែលមានឈ្មោះថា «BNKC Mobile App» នៅ ខែមិថុនា ឆ្នាំ២០២១។ អតិថិជនអាចទទួលបាន**ការប្រឹក្សាយោបល់ពីប្រាក់កម្ចី ស្នើសុំប្រាក់កម្ចី ត្រួតពិនិត្យតារាងសងប្រាក់** ព្រមទាំងអាច**ទូទាត់សង តាមរយៈ** Wing នៅលើទូរស័ព្ទដៃ ដោយមិនចាំបាច់មកកាន់គ្រឹះស្ថានដោយផ្ទាល់។

កម្មវិធីទូរស័ព្ទ ប៊ីអេនខេស៊ី ត្រូវបានបង្កើតឡើងជាមួយនឹង UI ដ៏សាមញ្ញសម្រាប់ការប្រើប្រាស់ដ៏ងាយស្រួលរបស់អ្នកប្រើប្រាស់ តាម រយៈការស្ទង់មតិ និងការធ្វើតេស្តរយៈពេលជាងមួយឆ្នាំ។ ការបើកដំណើរការនៃកម្មវិធីនេះ មានអត្ថប្រយោជន៍ចំពោះទាំងគ្រឹះស្ថាន និងអ្នកប្រើប្រាស់។ អ្នកប្រើប្រាស់អាចស្នើសុំ និងគ្រប់គ្រងប្រាក់កម្ចីបានកាន់តែឆ្លាតវៃ ហើយលើសពីនេះទៀត វាអាចជួយនិងអាចជៀសវាងការប៉ះពាល់ក្រដាសប្រាក់ដោយផ្ទាល់ ក្នុងកំឡុងពេលកាត់បន្ថយហានិភ័យ ការរាតត្បាតជាសកល នៃជំងឺកូវីដ-១៩នេះ។

គិតត្រឹមខែធ្នូ ឆ្នាំ២០២១ អ្នកប្រើប្រាស់ជាង ៦,៦០០នាក់បានដំឡើងកម្មវិធីទូរស័ព្ទ «BNKC Mobile App» នៅលើប្រព័ន្ធប្រតិបត្តិការ Android និង iOS ។ កម្មវិធីនេះនៅតែកំពុងអភិវឌ្ឍន៍ ដោយធ្វើការឆ្លុះបញ្ចាំង និងកែប្រែតាមតម្រូវការរបស់អ្នកប្រើប្រាស់ សម្រាប់ការស្នើសុំកម្ចី និងគ្រប់គ្រងកម្ចីឲ្យបានកាន់តែងាយស្រួល។ ទៅថ្ងៃអនាគត សង្ឃឹមថាប្រជាពលរដ្ឋកម្ពុជាទាំងអស់នឹងអាចប្រើប្រាស់សេវាកម្ចីកាន់តែលឿន និងងាយស្រួលជាងមុនតាមរយៈកម្មវិធីទូរស័ព្ទ «BNKC Mobile App» ។






# រចនាសម្ព័ន្ធគ្រឹះស្ថាន



# គណៈគ្រប់គ្រងកំពូល



## លោក KIM SOONJO
អគ្គនាយកប្រតិបត្តិ

លោក Kim Soonjo បានចាប់ផ្តើមបម្រើការងារនៅគ្រឹះស្ថាននៅដើមខែតុលា ឆ្នាំ២០២០ ក្នុងមុខតំណែងជាអគ្គនាយកប្រតិបត្តិ។ លោកមានបទពិសោធន៍បម្រើការងារនៅក្នុង ប៊ីអេនខេស៊ី មីយ៉ាន់ម៉ា រយៈពេល៦ឆ្នាំ ក្នុងមុខដំណែងជាអគ្គនាយកប្រតិបត្តិ។ មុនចូលបម្រើការងារក្នុងប៊ីអេនខេស៊ី មីយ៉ាន់ម៉ា លោកជានាយកគ្រប់គ្រងសាខា Daejeon របស់ក្រុមហ៊ុន BNK Capital រយៈពេល៤ឆ្នាំ ហើយក៏ធ្លាប់បម្រើការងារនៅក្នុងក្រុមហ៊ុន Aju Capital រយៈពេល ៦ឆ្នាំ ក្នុងមុខដំណែងដូចជា ប្រធានផ្នែកលក់ ប្រធានគ្រប់គ្រង ឥណទានជាដើម។ លោកមានបទពិសោធន៍ និងជំនាញក្នុងវិស័យហិរញ្ញវត្ថុនេះជាង ១៥ឆ្នាំហើយ។



## លោក LEE SIHYUN
អគ្គនាយករង

លោក LEE Sihyun បានចាប់ផ្តើមការងារនៅគ្រឹះស្ថាន នៅខែកក្កដា ឆ្នាំ ២០១៩។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យជាតិភុក្យុងនៃសាធារណរដ្ឋកូរ៉េ នៅឆ្នាំ១៩៩៨។ លោកមានបទពិសោធន៍ជាច្រើនឆ្នាំទាក់ទងនឹងវិស័យហិរញ្ញវត្ថុនៅសាធារណរដ្ឋកូរ៉េ។ លោកបានបម្រើការងារនៅធនាគារ Busan Parangsae Saving Bank អស់រយៈពេល៤ឆ្នាំ ក្នុងតួនាទីជាប្រធានគ្រប់គ្រងឥណទាន។ លោកបានចូលបម្រើការងារនៅ BNK Capital ក្នុងខែតុលា ឆ្នាំ២០១១ យោងទៅលើលទ្ធផលការងារដ៏ឆ្នើមជាច្រើនរបស់លោកនៅ BNK Capital លោកត្រូវបានតែងតាំងអោយកាន់តំណែងក្នុងផ្នែកគ្រប់គ្រងជាច្រើនបន្តបន្ទាប់គ្នាដូចជា គ្រប់គ្រងប្រឹក្សាយោបល់អតិថិជន គ្រប់គ្រងគម្រោងឥណទាន គ្រប់គ្រងត្រួតពិនិត្យឥណទាន និង គ្រប់គ្រងផ្នែកគ្រប់គ្រងហានិភ័យ។



## លោក KIM HYOBIN
ប្រធាននាយកគ្រប់គ្រងរដ្ឋបាល

លោក KIM Hyobin បានចូលបម្រើការងារក្នុងគ្រឹះស្ថាន នៅខែកញ្ញាឆ្នាំ ២០២១ ក្នុងមុខតំណែងជាប្រធាននាយកគ្រប់គ្រងរដ្ឋបាល។ លោកបានបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រ ផ្នែកសុខុមាលភាពសង្គមពីសាកលវិទ្យាល័យ Kyunghee Cyber នៃសាធារណរដ្ឋកូរ៉េ។ លោកបានចាប់ផ្តើមអាជីពការងារនៅ BNK Capital នៅឆ្នាំ២០១៤ ក្នុងតំណែងជាមន្ត្រីផ្នែកទីផ្សារ។ កំឡុងពេល៨ឆ្នាំ លោកបានចូលរួមគម្រោងការងារជាច្រើន ដូចជាគម្រោងអភិវឌ្ឍន៍កម្មវិធីទូរស័ព្ទដៃ គម្រោងអភិវឌ្ឍន៍ផលិតផលប្រាក់កម្ចី ជាដើម។ ការខិតខំប្រឹងប្រែង និងលិទ្ធផលការងារដ៏ឆ្នើមរបស់លោកបានចូលរួមចំណែកយ៉ាងច្រើនដល់ក្រុមហ៊ុនក្នុងអំឡុងពេលនោះ។ លោកត្រូវបានផ្ទេរទៅក្រុម Retail Sales Support មានមុខតំណែងជាប្រធានគ្រប់គ្រង ហើយបានធ្វើការជាមួយក្រុមហ៊ុនរហូតដល់លោកក្លាយជានាយកគ្រប់គ្រង Retail Planning Team នៅឆ្នាំ ២០២១។



# គណៈគ្រប់គ្រង



គណៈគ្រប់គ្រង ប៊ីអេនខេស៊ី



## កញ្ញា ពៅ សាឡឹម

### ប្រធាននាយកដ្ឋានផែនការ

កញ្ញា ពៅ សាឡឹម មានមុខតំណែងជាប្រធាននាយកដ្ឋានផែនការ។ កញ្ញាបានចូលបម្រើការងារក្នុងគ្រឹះស្ថាន នៅខែមករា ឆ្នាំ២០១៦ ជាជំនួយការអគ្គនាយកប្រតិបត្តិ។ មុនការចាប់អាជីពនៅគ្រឹះស្ថានប៊ីអេនខេស៊ី កញ្ញាធ្លាប់ធ្វើជាប្រធាននាយករដ្ឋបាលនៅសាលាអន្តជាតិមួយរយៈពេល២ឆ្នាំ។ កញ្ញាក៏ធ្លាប់ជាចូលរួមក្នុងគម្រោងសិក្សាស្រាវជ្រាវ និងវិភាគជាច្រើនលើផ្នែកអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនៅសាធារណរដ្ឋកូរ៉េមុនត្រឡប់មកប្រទេសកម្ពុជាវិញ។ កញ្ញា ពៅ សាឡឹមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញរដ្ឋបាលសាធារណៈ នៅឆ្នាំ២០១៤ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួនពីរ ផ្នែកសេដ្ឋកិច្ច និងផ្នែករដ្ឋបាលសាធារណៈនៅសាកលវិទ្យាល័យស្ត្រី Ewha នៅសាធារណរដ្ឋប្រទេសកូរ៉េ នៅឆ្នាំ២០១១។



## លោក អ៊ុន រតនៈ

### ប្រធាននាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល

លោក អ៊ុន រតនៈ មានមុខតំណែងជាប្រធាននាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល។ លោកបានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែមិថុនា ឆ្នាំ២០១៦។ មុនការចាប់អាជីពនៅគ្រឹះស្ថានប៊ីអេនខេស៊ី លោកធ្លាប់ធ្វើជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងជាជំនួយការប្រធានគម្រោងនៅក្រុមហ៊ុនសាងសង់អស់រយៈពេល៣ឆ្នាំ។ លោកក៏ធ្លាប់ជានាយកគ្រប់គ្រងសាលារៀន នៃអង្គការ ICMS Mission Society ដែលមានមូលដ្ឋាននៅប្រទេសថៃរយៈពេល១ឆ្នាំ។

លោក អ៊ុន រតនៈ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងធុរៈកិច្ចពីសកលវិទ្យាល័យ បៀលប្រាយ នៅក្នុងខែមីនា ឆ្នាំ២០១៥។ ក្នុងឆ្នាំ២០១២ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួនពីរផងដែរ ទីមួយផ្នែកអន្តរវប្បធម៌ និងទីពីរផ្នែកអក្សរសាស្ត្រភាសាអង់គ្លេសពីសាកលវិទ្យាល័យ KOSIN នៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ។ ក្រៅពីនេះ លោកបានសិក្សាវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស វិជ្ជាជីវៈស្តីពីភាពជាអ្នកដឹកនាំ ការគ្រប់គ្រងរដ្ឋបាល និងការិយាល័យ ច្បាប់ស្តីពីការងារនិងការប្រតិបត្តិតាមច្បាប់ ការសរសេរគោលនយោបាយ និងគោលការណ៍គ្រប់គ្រង់ធនធានមនុស្ស ការគ្រប់គ្រងលទ្ធផលការងារនិយោជិក និងការគ្រប់គ្រងធនធានមនុស្ស ។ល។



## លោក ផេង ភ័ក្រ្ត

### ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ

លោក ផេង ភ័ក្រ្ត បានចូលបម្រើការងារនៅ គ្រឹះស្ថាន ក្នុងខែសីហា ឆ្នាំ២០១៩ មុខតំណែងជា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ។ លោកមានបទពិសោធន៍ការងារក្នុងវិស័យមីក្រូហិរញ្ញវត្ថុរយៈពេលលើស១៥ឆ្នាំ។ មុនចាប់អាជីពការងារជាមួយ គ្រឹះស្ថាន ប៊ីអេនខេស៊ី លោកធ្លាប់ធ្វើការនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងក្រុមហ៊ុនអន្តរជាតិ ក្នុងមុខតំណែងជាច្រើនដូចជា សវនករផ្ទៃក្នុង គណនេយ្យករជាន់ខ្ពស់ គណនេយ្យករគ្រប់គ្រងជាន់ខ្ពស់ ប្រធានត្រួតពិនិត្យហិរញ្ញវត្ថុ ប្រធានវិភាគអាជីវកម្ម ប្រធានរៀបចំផែនការថវិកា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល ហើយលោកក៏មានបទពិសោធក្នុងការប្តូរប្រព័ន្ធធនាគារស្នូល ការធ្វើឲ្យកាន់តែប្រសើរនូវប្រព័ន្ធការងារ និងជាគ្រូបង្រៀននៅសាកលវិទ្យាល័យ រយៈពេលប្រាំមួយឆ្នាំ មុខវិជ្ជាគណនេយ្យ និងសវនកម្ម ផងដែរ ។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងហិរញ្ញវត្ថុ ពីសកលវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០១១ និងបញ្ចប់ថ្នាក់បរិញ្ញបត្រ ហិរញ្ញវត្ថុ និងគណនេយ្យ ព្រមទាំងថ្នាក់បរិញ្ញបត្រអក្សរសាស្ត្រភាសាអង់គ្លេស ពី សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យន័រតុន និងកំពុងបន្តការសិក្សាជំនាញគណនេយ្យករអាជីព។ ក្រៅពីនេះលោកបានសិក្សាវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ ស្តីពីការវិភាគសូចនាករប្រតិបត្តិហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល ការគ្រប់គ្រងហានិភ័យរបាយការណ៍តុល្យការ ការបង្ហាញហានិភ័យឥណទាន ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ប្រព័ន្ធពន្ធដារកម្ពុជា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ កម្មវិធីអភិវឌ្ឍអ្នកគ្រប់គ្រង ភាពជាអ្នកដឹកនាំ និងការលើកទឹកចិត្ត ។ល។



## លោក ពៅ ច័ន្ទមិថុនា

ប្រធាននាយកដ្ឋានវិភាគឥណទាន

លោក ពៅ ច័ន្ទមិថុនា មានមុខតំណែងជាប្រធាននាយកដ្ឋានវិភាគឥណទាន។ លោកបានចូលបម្រើការងារក្នុងគ្រឹះស្ថាន នៅខែមិថុនា ឆ្នាំ២០២០។ មុនលោកចាប់អាជីពនៅគ្រឹះស្ថានប៊ីអេនខេស៊ី លោកធ្លាប់បម្រើការងារនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុជាច្រើនមុខតំណែងដូចជា ប្រធានគ្រប់គ្រងប្រាក់កម្ចី ប្រធានភ្នាក់ងារឥណទាននៅតាមបណ្តាធនាគារដ៏ឈានមុខមួយចំនួននៅប្រទេសកម្ពុជា។ លោកមានបទពិសោធន៍ និងចំណេះដឹងខាងវិស័យហិរញ្ញវត្ថុអស់រយៈពេលជាង ១0ឆ្នាំ។

លោក ពៅ ច័ន្ទមិថុនាបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងខែសីហា ឆ្នាំ២០១៥។ នៅក្នុងឆ្នាំ២០០៩ លោកបានបញ្ចប់ថ្នាក់ បរិញ្ញបត្រ ជំនាញធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ នៅឆ្នាំ២០០៦ លោកបានបញ្ចប់ថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងធនាគារ នៅមណ្ឌលសិក្សា បច្ចេកទេសធនាគារ។



## លោក ហាក់ សែនសុភក្តិ

ប្រធាននាយកដ្ឋានឥណទាន

លោក ហាក់ សែនសុភក្តិបានចាប់ផ្តើមចូលបម្រើការងារនៅគ្រឹះស្ថាន នៅក្នុងខែឧសភា ឆ្នាំ២០១៩។ លោកមានបទពិសោធន៍ជាង១៦ឆ្នាំក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ។ លោកធ្លាប់ជានាយកសាខានៅធនាគារមួយអស់រយៈពេល៧ឆ្នាំ និងជានាយកប្រតិបត្តិការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអស់រយៈពេល៣ឆ្នាំ។ លោកមានពហុជំនាញក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុដូចជាជំនាញគ្រប់គ្រងឥណទាន វិភាគហានិភ័យឥណទាន ការត្រួតពិនិត្យឥណទាន ការត្រួតពិនិត្យព័ត៌មានCBC ជំនាញដោះស្រាយបំណុល គ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យជាដើម។

លោក ហាក់ សែនសុភក្តិបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងធុរៈកិច្ចនៅសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០០៩ និងបរិញ្ញាបត្រសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មនៅឆ្នាំ២០០៥។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗទៀតដូចជា សិទ្ធិមនុស្ស អភិបាលកិច្ចល្អភាពជាអ្នកដឹកនាំ ច្បាប់ការងារ និងនិយោជិកជំនាញគណនេយ្យជាដើម។



## កញ្ញា សៀ ណៃឡេង

ប្រធាននាយកដ្ឋានប្រតិបត្តិតាម

កញ្ញា សៀ ណៃឡេង មានមុខតំណែងជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។ កញ្ញាបានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែមករា ឆ្នាំ២០១៩។ មុនពេលចាប់ផ្តើមអាជីពនៅគ្រឹះស្ថាន កញ្ញាធ្លាប់បម្រើការងារជាជំនួយការមេធាវី និងជាមន្ត្រីប្រតិបត្តិតាមនៅគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុមួយ។ កញ្ញាក៏ធ្លាប់ជាអ្នកប្រឹក្សាផ្នែកច្បាប់ និងស្រាវជ្រាវផ្នែកច្បាប់។ កញ្ញាត្រូវបានទទួលស្គាល់ជាផ្លូវការពីធនាគារជាតិនៃកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្នុងមុខងារជាមន្ត្រីប្រតិបត្តិតាម។

កញ្ញា សៀ ណៃឡេង បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៧ និងបានបញ្ចប់ថ្នាក់ភាសារអង់គ្លេសទូទៅពី សាកលវិទ្យាល័យបញ្ញាស្រ្តកម្ពុជាផងដែរ។ ក្រៅពីនេះ កញ្ញាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ Regulatory Compliance និង Anti-Money Laundering នៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា -ល- ។



## លោក អ៊ុម សុបុត្រា

ប្រធាននាយកដ្ឋានដោះស្រាយបំណុល

លោក អ៊ុម សុបុត្រា មានមុខតំណែងជាអនុប្រធាននាយកដ្ឋានដោះស្រាយបំណុល។ លោកបានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែសីហា ឆ្នាំ២០១៥ ដែលជាឆ្នាំបង្កើតគ្រឹះស្ថាន។ លោកមានបទពិសោធន៍ការងារក្នុងវិស័យគ្រឹះស្ថានហិរញ្ញវត្ថុ រយៈពេលជាង១១ឆ្នាំ ។ មុនចាប់អាជីពការងារជាមួយគ្រឹះស្ថាន លោកធ្លាប់បម្រើការងារនៅធានាគារ អេស៊ីលីដា ភីអិលស៊ីអស់ រយៈពេលជាង១១ ឆ្នាំ មានមុខងារជាមន្ត្រីឥណទាន និងជាសវនករផ្ទៃក្នុងជាង១ឆ្នាំ ។
លោក អ៊ុម សុបុត្រា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសផ្នែកហិរញ្ញវត្ថុ ពីសកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងឆ្នាំ២០១៨ និងបញ្ចប់ថ្នាក់បរិញ្ញបត្រ ជំនាញគ្រប់គ្រងក្នុងឆ្នាំ២០០៣ នៅវិទ្យាស្ថានជាតិគ្រប់គ្រង ។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលមួយចំនួនដូចជា ការរៀបចំបណ្តឹង វិភាគប្រតិបត្តិការគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងភាពជោគជ័យនៃការលក់ រួមទាំងសិទ្ធិមនុស្ស ជាដើម ។ល។



## លោក អាន សុខខាក់

ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា

លោក អាន សុខខាក់ បានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែមេសា ឆ្នាំ២០១៥។ មុនចូលបម្រើការនៅគ្រឹះស្ថាន លោកធ្លាប់ជាមន្ត្រីគ្រប់គ្រង Database នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ រយៈពេល២ឆ្នាំ និងជាអ្នកអភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រក្នុងក្រុមហ៊ុនមួយ រយៈពេល២ឆ្នាំ។ លោកក៏ធ្លាប់ជាបុគ្គលិកផ្នែកសម្របសម្រួលព័ត៌មានវិទ្យានៅសាលាអន្តរជាតិមួយ រយៈពេល១ឆ្នាំ និងជាគ្រូបង្រៀនអភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រផងដែរ។
លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញវិស្វកម្ម និងបច្ចេកទេសកុំព្យូទ័រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០០៩។ លោកបានចូលរួមវគ្គបណ្តុះបណ្តាល ជំនាញបច្ចេកវិទ្យាជាច្រើនផ្នែកដូចជា C-Programming, C++, Java, C#, VB.net, PHP, MySQL, SQL Server, Database Management System and IT Project Managem-ent។



## លោក រឿន រិទ្ធា

ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

លោក រឿន រិទ្ធា បានចូលបម្រើការងារនៅគ្រឹះស្ថាននៅខែឧសភា ឆ្នាំ២០១៩។ លោកចាប់ផ្តើមអាជីពជាសវនករផ្ទៃក្នុង នៅវិស័យធនាគារ និងហិរញ្ញវត្ថុអស់រយៈពេលជាង ១២ឆ្នាំ។ មុនបម្រើការងារនៅគ្រឹះស្ថាន លោកធ្លាប់ជាសវនករផ្ទៃក្នុងនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសីលានិធិរយៈពេល៤ឆ្នាំ និងសវនករផ្ទៃក្នុងជាន់ខ្ពស់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ីរយៈពេល៥ឆ្នាំ។
លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យន័រតុនក្នុងឆ្នាំ២០០៩។ ដើម្បីបំពេញបន្ថែមនូវចំណេះដឹងផ្នែកសវនកម្ម លោកបានចូលរួមវគ្គសិក្សាខ្លីជាច្រើនដូចជា ការត្រួតពិនិត្យផ្ទៃក្នុង និងការការពារហានិភ័យនៃការក្លែងបន្លំ ច្បាប់ពន្ធដារកម្ពុជា ការគ្រប់គ្រងសវនកម្មផ្ទៃក្នុង ច្បាប់កិច្ចសន្យា និងកិច្ចព្រមព្រៀងប្រាក់កម្ចីក្នុងប្រតិបត្តិការហិរញ្ញវត្ថុ និងមូលដ្ឋានគ្រឹះនៃសវនកម្មផ្ទៃក្នុងជាដើម។

# ការអភិវឌ្ឍសមត្ថភាពបុគ្គលិក

**ការអភិវឌ្ឍសមត្ថភាពបុគ្គលិក** គឺជាកម្លាំងជំរុញដ៏រឹងមាំដែលអាចនាំឲ្យក្រុមហ៊ុនឈានទៅមុខក្លាយជាក្រុមហ៊ុនដែលមានការរីកចម្រើនជាបន្តបន្ទាប់។ នៅក្នុងសង្គមសម័យទំនើបនេះ ភាពជោគជ័យអាស្រ័យទៅលើរបៀបប្រើប្រាស់ចំណេះដឹង និងរបៀបប្រាស្រ័យទាក់ទងជាមួយមនុស្សជុំវិញខ្លួន។

ប៉ុន្តែ នៅឆ្នាំ ២០២១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី មិនអាចមានការ បណ្តុះបណ្តាលដូចពីមុនបានទេ ដោយសារមានការបិទខ្ទប់តំបន់ ក្នុងពេលកំពុងមានការព្រួយបារម្ភពីការឆ្លងនៃមេរោគកូវីឌ-១៩។ ទោះជាយ៉ាងណាក្តី ស្ថិតក្នុងអំឡុងពេលបិទខ្ទប់ គ្រឹះស្ថានមិនបោះបង់ចោលការចែករំលែក និងទំនាក់ទំនងគ្នាឡើយ ដូចពាក្យស្លោកដែលបានពោលថា «ទឹកដែលនៅទ្រឹងនឹងក្លាយទៅជាទឹកស្អុយ តែទឹកដែលហូរនឹងជួយឲ្យមានជីវិតកើតឡើង» គឺយើងនៅតែបង្កើតអោយមានការ បណ្តុះបណ្តាលតាមអ៊ីនធឺណែត និងក្រៅបណ្តាញដែលត្រូវបានធ្វើឡើងអនុលោមតាមគោលការណ៍ រដ្ឋាភិបាលដោយអនុវត្ត «៣កុំ ៣ការពារ» ។



បុគ្គលិក ប៊ីអេនខេស៊ី

# ការបណ្តុះបណ្តាលផ្ទៃក្នុង





នាយកដ្ឋានព័ត៌មានវិទ្យា

**ការបណ្តុះបណ្តាលផ្ទៃក្នុង៖** ដើម្បីការពារពីការរីករាលដាលកូវីដ-១៩ បុគ្គលិកតម្រូវអោយឆ្លាស់វេនធ្វើការពីផ្ទះមួយរយៈពេល នេះជាឱកាសល្អមួយដែលអាចបង្ហាញពីទំនួលខុសត្រូវរបស់បុគ្គលិកម្នាក់ៗទៅលើការងាររបស់ពួកគេ ក៏ដូចជាទំនុកចិត្តរបស់គ្រឹះស្ថានទៅលើបុគ្គលិកម្នាក់ៗ ។ ទន្ទឹមគ្នានេះ គ្រឹះស្ថានបានធ្វើការបណ្តុះបណ្តាលផ្ទៃក្នុងដល់បុគ្គលិកទាំងមូល ទាំងបុគ្គលិកចាស់ និងបុគ្គលិកថ្មី ការបណ្តុះបណ្តាលនេះមិនត្រឹមតែពង្រឹងការយល់ដឹងអំពីការងារអោយកាន់តែច្បាស់លាស់ប៉ុណ្ណោះទេ ថែមទាំងបង្ហាត់អំពីផ្នត់គំនិត និងក្រមសីលធម៌ការងារត្រឹមត្រូវផងដែរ។ ការបណ្តុះបណ្តាលផ្ទៃក្នុងនេះត្រូវបានធ្វើឡើងដោយគណៈគ្រប់គ្រង បុគ្គលិកឆ្នើម ឬបុគ្គលិកដែលមានជំនាញរបស់គ្រឹះស្ថាន ដើម្បីពង្រឹងការយល់ដឹងត្រឹមត្រូវលើគោលការណ៍ និងសេចក្តីណែនាំ របស់គ្រឹះស្ថាន។

នៅឆ្នាំ២០២១នេះ ការបណ្តុះបណ្តាលជាលក្ខណៈផ្ទៃក្នុងមានដូចខាងក្រោម៖

### នាយកដ្ឋានធនធានមនុស្សនិងរដ្ឋបាល

- សេចក្តីណែនាំពីប៊ីអេនខេស៊ីជូនដល់បុគ្គលិកថ្មីៗ
- អត្ថប្រយោជន៍បុគ្គលិក

### នាយកដ្ឋានហិរញ្ញវត្ថុ

- គោលនយោបាយហិរញ្ញវត្ថុ
- សេចក្តីណែនាំពី ការចំណាយហិរញ្ញវត្ថុ និងរដ្ឋបាល
- ការត្រួតពិនិត្យហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព
- ការគ្រប់គ្រងលំហូរសាច់ប្រាក់
- សេចក្តីណែនាំអំពីការទម្លាក់ និងប្រមូលឥណទាន
- សេចក្តីណែនាំអំពីការបំពេញចិត្តអតិថិជន
- ការពិនិត្យមើលរូបិយវត្ថុក្លែងក្លាយ

### នាយកដ្ឋានវិភាគឥណទាន

- ការវិភាគឥណទាន
- ការវិភាគហានិភ័យ
- របៀបពិនិត្យរបាយការណ៍ CBC
- ការប្រើប្រាស់ប្រព័ន្ធវិភាគឥណទាន

### នាយកដ្ឋានប្រតិបត្តិការ

- គោលនយោបាយឥណទាន
- ការគ្រប់គ្រងហានិភ័យឥណទាន
- ការវាយតម្លៃឥណទាន
- ជំនាញលក់ផលិតផលឥណទាន
- យុទ្ធសាស្ត្រប្រតិបត្តិការ

### នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

- ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

### ប្រធាននាយកដ្ឋានដោះស្រាយបំណុល

- គោលនយោបាយប្រឆាំងការក្លែងបន្លំ
- គោលការណ៍ដោះស្រាយបំណុល
- នីតិវិធីនៃការដោះស្រាយបំណុល

### នាយកដ្ឋានព័ត៌មានវិទ្យា

- តួនាទីអាជីវកម្មរបស់ BNKC
- UI នៃ BNKC Sub System
- មូលដ្ឋានទិន្នន័យក្នុង BNKC Sub System
- UI នៃ BNK Banking System
- មូលដ្ឋានទិន្នន័យក្នុង BNK Banking System





នាយកដ្ឋានព័ត៌មានវិទ្យា


នាយកដ្ឋានឥណទាន


នាយកដ្ឋានឥណទាន


នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល


នាយកដ្ឋានព័ត៌មានវិទ្យា


ការបណ្តុះបណ្តាលប្រព័ន្ធ


បណ្តុះបណ្តាលពីផ្ទះ តាមអនឡាញ



# វគ្គបណ្តុះបណ្តាលខាងក្រៅ

ក្រៅការពីការបណ្តុះបណ្តាលផ្ទៃក្នុង គ្រឹះស្ថានក៏បានបញ្ជូនបុគ្គលិកទៅចូលរួមវគ្គ បណ្តុះបណ្តាលខាងក្រៅ និងសិក្ខាសាលាជាច្រើនដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា សហគមមីក្រូហិរញ្ញវត្ថុកម្ពុជា វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ និងHome-Ducation ជាដើម។ តាមរយៈការបណ្តុះបណ្តាលនិយោជិកទទួលបាននូវការពង្រឹងចំណេះដឹង ការគិតបែបយុទ្ធសាស្ត្រ ការធ្វើផែនការ និងលើកកម្ពស់វិជ្ជាជីវៈដែលត្រូវការចាំបាច់ដើម្បីបុគ្គលិកអាចសម្រេចបាននូវការបំពេញភារកិច្ច ប្រកបដោយប្រសិទ្ធភាព។

| ប្រធានបទបណ្តុះបណ្តាល | បុគ្គលិកចូលរួម | រៀបចំដោយ | កាលបរិច្ឆេទ |
|---|---|---|---|
| ការគ្រប់គ្រងធនធាន និងប្រតិបត្តិតាមក្នុងគ្រឹះស្ថានហិរញ្ញវត្ថុ | អនុប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល | CMA | ថ្ងៃទី២២ ខែឧសភា |
| ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យម | អនុប្រធាន ផ្នែកនាយកដ្ឋានហិរញ្ញវត្ថុ | CMA | ថ្ងៃទី២៩ ខែឧសភា |
| ការគ្រប់គ្រងលទ្ធផលការងាររបស់បុគ្គលិក | នាយកធនធានមនុស្ស និងរដ្ឋបាល | CMA | ថ្ងៃទី២៤ ខែកក្កដា |
| ការវិភាគហានិភ័យហិរញ្ញវត្ថុ | អនុប្រធាន សវនកម្មផ្ទៃក្នុង | IBF | ថ្ងៃទី៣០ ខែវិច្ឆិកា |
| យុទ្ធសាស្ត្ររើស រៀប និងរក្សាបុគ្គលិក | នាយកធនធានមនុស្ស និងរដ្ឋបាល | Home-Ducation | ថ្ងៃទី៧ ១១ ១៧ ខែធ្នូ |
| ច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា និងប្រតិបត្តិតាម | អនុប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល | Phnom Penh Business School | ១៧-១៨ ខែធ្នូ |



នាយកដ្ឋានសវនកម្មផ្ទៃក្នុង


នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល


នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល





នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល



# សុវត្ថិភាពសុខភាពនៅកន្លែងការងារក្នុងអំឡុងពេលកូវីដ១៩

នៅក្នុងខែមេសា ឆ្នាំ២០២១ ជំងឺកូវីដ-១៩ បានរីករាលដាលយ៉ាងខ្លាំង ចាប់ផ្តើមពីរាជធានីភ្នំពេញរហូតដល់ទូទាំងប្រទេសកម្ពុជា។ និយោជិកទាំងអស់តែងតែលាងសម្អាតដោយទឹកអាល់កុល នៅទីកន្លែងធ្វើការប្រចាំថ្ងៃ ដូចជាការិយាល័យ សាលប្រជុំ ច្រករបៀង បន្ទប់ទឹកជាដើម។ មិនតែប៉ុណ្ណោះ គ្រឹះស្ថានបានប្រើប្រាស់ក្រុមហ៊ុនឯកទេសខាងសម្លាប់មេរោគ ឱ្យធ្វើការសម្លាប់មេរោគនៅក្នុងអាគារគ្រឹះស្ថានទាំងមូល។ ក្រុមហ៊ុនក៏បានរៀបចំឧបករណ៍សម្លាប់មេរោគនៅក្នុងគ្រឹះស្ថានដើម្បីទប់ស្កាត់មេរោគឆ្លង ក្នុងករណីដែលមានអ្នកជំងឺ ឬ អ្នកពាក់ព័ន្ធផ្ទាល់ជាមួយអ្នកជំងឺចូលមកក្នុងគ្រឹះស្ថាន។

រូបភាពខាងក្រោមនេះ បង្ហាញពីសកម្មភាពសម្លាប់មេរោគនៅទីស្នាក់ការកណ្តាល និងគ្រប់សាខាដែលធ្វើឡើងជាបន្តបន្ទាប់ក្នុងរយៈពេលពេញមួយឆ្នាំ ២០២១ ។











សកម្មភាពសម្លាប់មេរោគ






ប្រគល់សម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃដល់បុគ្គលិកដែលរស់នៅក្នុងតំបន់បិទខ្ទប់ពណ៌ក្រហម។

យើងអាចនិយាយបានថា សកម្មភាពធំៗសំខាន់របស់ BNKC ចាប់ផ្តើមពីការជួបអតិថិជនដោយផ្ទាល់ការណែនាំ និងពិគ្រោះយោបល់ពីប្រាក់កម្ចីដល់អតិថិជន។ អាស្រ័យហេតុនេះ គ្រឹះស្ថានបានធ្វើតេស្តរហ័ស (Rapid Test) សម្រាប់បុគ្គលិកទាំងអស់ជារៀងរាល់ថ្ងៃចន្ទ សម្រាប់បុគ្គលិកមាន លទ្ធផលវិជ្ជមានត្រូវដាក់ឱ្យនៅដាច់ដោយឡែក ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់បុគ្គលិកដែលរស់នៅក្នុងតំបន់ក្រហម ឬ បុគ្គលិកធ្វើការពីផ្ទះដោយសារវិជ្ជមានជំងឺកូវីដ-១៩ ឬ ធ្លាប់ពាក់ព័ន្ធផ្ទាល់ គ្រឹះស្ថានបានផ្តល់ការ គាំទ្រយ៉ាងខ្លាំង ដោយប្រើគ្រប់មធ្យោបាយដែលអាចផ្តល់ជូនដល់បុគ្គលិក។ លើសពីនេះ គ្រឹះស្ថានបានប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីការពារកូវីដ-១៩ តាមរយៈការសម្លាប់មេរោគជាប្រចាំនៅគ្រប់សាខា ការផ្តល់ម៉ាស់ និងថ្នាំសម្លាប់មេរោគ និងការផ្តល់ឧបករណ៍ប្រមូលផ្តុំអុកស៊ីសែន Krorber 4.0 ជាដើម ។




នាយកប្រតិបត្តិប្រគល់សម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃដើម្បីឲ្យបុគ្គលិកដែលរស់នៅតំបន់បិទខ្ទប់ត្រៀមលក្ខណៈធ្វើការពីផ្ទះបាន។



ធ្វើការពីផ្ទះ



គ្រឹះស្ថានបានធ្វើតេស្តរហ័ស (Rapid Test) សម្រាប់បុគ្គលិកទាំងអស់ជារៀងរាល់ថ្ងៃចន្ទ

# ទំនួលខុសត្រូវផ្នែកសង្គម

ទន្ទឹមនឹងនេះ រដ្ឋាភិបាលបានប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការរក្សាសុវត្ថិភាពប្រជាពលរដ្ឋដោយការអនុវត្តគោលការណ៍ការពារ និងបានទិញវ៉ាក់សាំងពីបរទេសដើម្បីជួយប្រជាពលរដ្ឋទាំងអស់អាចទទួលបានវ៉ាក់សាំងការពារជំងឺកូវីដ-១៩។ គ្រឹះស្ថានក៏បានបរិច្ចាគទឹកប្រាក់សម្រាប់គាំទ្រដល់រដ្ឋាភិបាលក្នុងការជួយប្រជាជនកម្ពុជាឲ្យមានសុវត្ថិភាពពីជំងឺកូវីដ១៩ តាម រយៈការចាក់វ៉ាក់សាំង។ សុវត្ថិភាពជាចំបង!






# របាយការណ៍សវនកម្មឯករាជ្យ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១


34 របាយការណ៍សវនកម្មឯករាជ្យ

**របាយការណ៍ហិរញ្ញវត្ថុ**

37 របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

38 របាយការណ៍ចំណូលលម្អិត

39 របាយការណ៍បម្រែបម្រួលមូលធន

40 របាយការណ៍លំហូរសាច់ប្រាក់

# របាយការណ៍របស់សវនកម្មឯករាជ្យ

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
**លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០**
www.grantthornton.com.kh

**ជូនចំពោះភាគទុនិករបស់**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី(ខេមបូឌា) ភីអិលស៊ី**

## មតិយោបល់

យើងបានធ្វើសវនកម្មទៅលើ របាយការណ៍ហិរញ្ញវត្ថុ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាកាលបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់នាកាលបរិច្ឆេទដែលបានបញ្ចប់ និងសេចក្តីសង្ខេបកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុផ្សេងៗ រួមទាំងគោលនយោបាយគណនេយ្យសង្ខេបសំខាន់ៗ និងសេចក្តីពន្យល់ផ្សេងៗ។

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់កាលបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (“CIFRS for SME”) និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា(“NBC”)។

## មូលដ្ឋាននៃមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិរបស់កម្ពុជា (“CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ។ យើងមានឯករាជ្យភាព លើក្រុមហ៊ុន ហើយអនុលោមតាមស្តង់ដារនៃវិជ្ជាជីវៈគណនេយ្យអន្តរជាតិ “ក្រមសីលធម៌របស់គណនេយ្យករជំនាញ” (“IESBA Code”) រួមជាមួយនិងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការ និង ក្រមសីលធម៌ទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មទាំងឡាយដែលយើងទទួលបានគឺគ្រប់គ្រាន់និងសមហេតុផលដើម្បីផ្តល់ជូនជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិរបស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ក៏ប៉ុន្តែមិនរាប់បញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំ ដែលទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករ និងរបាយការណ៍ប្រចាំឆ្នាំ ដែលត្រូវបានរំពឹងថាធ្វើឡើងបន្ទាប់ពីកាលបរិច្ឆេទនោះឡើយ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ។ យើងខ្ញុំមិនផ្តល់ការធានាក្នុងទម្រង់បែបណាមួយឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗដែលបានបញ្ជាក់ខាងលើ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនសង្គតិភាពជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬថាតើពត៌មានផ្សេងៗនេះបង្ហាញនូវកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើការអានព័ត៌មានផ្សេងៗនេះ ដែលយើងខ្ញុំបានទទួលមុនថ្ងៃនៃរបាយការណ៍សវនកររបស់យើងខ្ញុំ អាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងឆ្លើយតបលើបញ្ហាទាំងនេះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានកែប្រែ)។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំនិងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើសមត្ថភាពក្រុមហ៊ុន ក្នុងការបន្តប្រតិបត្តិការ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង ប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែក្រុមប្រឹក្សាភិបាលមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

## ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូល ពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង បញ្ចេញមតិលើរបាយការណ៍របស់សវនករ ដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់ ប៉ុន្តែវាមិនបានធានាថា ការធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិរបស់កម្ពុជា នឹងតែងតែរកឃើញកំហុសខុសឆ្គង នៅពេលវាកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ផ្នែកមួយនៃជាការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមន្ទិលជាគុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំនិងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹង ហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។

- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។

- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់ក្រុមប្រឹក្សាភិបាលលើមូលដ្ឋាននិរន្តរភាពគណនេយ្យ ផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់ក្រុមហ៊ុន។ ប្រសិនបើយើងសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវ័ន្តនឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវនឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញ របាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយ ស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានាថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ វិសាលភាពដែលបានគ្រោងទុក និង ពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតធំៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

**គ្រេ្គន សនថុន (ខេមបូឌា) លីមីធីត**
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ពាន់រៀល (កំណត់សម្គាល់ ៣.១) | ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ពាន់រៀល (កំណត់សម្គាល់ ៣.១) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់សុទ្ធ | ៥ | **២.៩៨៨.១៥៨** | **១២.១៧៣.៧៥៦** | ១.១៤២.៦២៥ | ៤.៦២១.៩១៨ |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិជាមួយ NBC | ៦ | **៧៥០.០០០** | **៣.០៥៥.៥០០** | ៧៥០.០០០ | ៣.០៣៣.៧៥០ |
| ឥណទានផ្តល់ដល់អតិថិជន សុទ្ធ | ៧ | **៦៩.០៤៩.៤៧៣** | **២៨១.៣០៧.៥៥៣** | ៣៩.៨៦៤.១៥១ | ១៦១.២៥០.៤៩១ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | **១.៤២៧.៥៧៨** | **៥.៨១៥.៩៥៣** | ១៦៧.៤៧៨ | ៦៧៧.៤៤៩ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ សុទ្ធ | ៩ | **៨១៥.៥០៤** | **៣.៣២២.៣៦៣** | ៥៩៤.០៧៤ | ២.៤០៣.០២៩ |
| ទ្រព្យសកម្មអរូបី សុទ្ធ | ១០ | **១៧៤.១០៣** | **៧០៩.២៩៦** | ១.៥៣៨ | ៦.២២១ |
| ពន្ធពន្យាលើទ្រព្យសកម្ម | ១៨.៤ | **៨៥.២៧៨** | **៣៤៧.៤២៣** | - | - |
| **ទ្រព្យសកម្មសរុប** | | **៧៥.២៨៦.៥៤១** | **៣០៦.៧១៧.៣៦៩** | ៤២.៥១៩.៨៦៦ | ១៧១.៩៩២.៨៥៨ |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១១ | **១៥.០០០.០០០** | **៦០.២៧០.០០០** | ១៥.០០០.០០០ | ៦០.២៧០.០០០ |
| ប្រាក់ចំណេញរក្សាទុក | | **២.២៨០.៨៧៦** | **៩.៤៣៧.០០៥** | ១៣.២៦៣ | ២១២.៣៥៦ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ១២ | **១៩០.៦១៨** | **៧៧២.៤៧៦** | ១៥១.៨៩០ | ៦១៤.៩៣០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | | | **៦៩៩.៣៨៧** | - | ២៤៥.៧៥៨ |
| **មូលធនសរុប** | | **១៧.៤៧១.៤៩៤** | **៧១.១៧៨.៨៦៨** | ១៥.១៦៥.១៥៣ | ៦១.៣៤៣.០៤៤ |
| **បំណុល** | | | | | |
| ប្រាក់កម្ចី | ១៣ | **៥៦.៦៩២.៣០៨** | **២៣០.៩៦៤.៤៦៣** | ២៦.៨៤៥.៩៨២ | ១០៨.៥៩១.៩៩៧ |
| គណនីត្រូវសងផ្សេងៗ | ១៤ | **៣៩៦.២៧៣** | **១.៦១៤.៤១៦** | ១៩៤.២០១ | ៧៨៥.៥៤៣ |
| ពន្ធលើប្រាក់ចំណូលត្រូវសង | ១៨.៣ | **៧២៤.៦០៤** | **២.៩៥២.០៣៧** | ៣១៤.៥៣០ | ១.២៧២.២៧៤ |
| **បំណុលសរុប** | | **៥៧.៨១៥.០៤៧** | **២៣៥.៥៣៨.៥០១** | ២៧.៣៥៤.៧១៣ | ១១០.៦៤៩.៨១៤ |
| **មូលធន និងបំណុលសរុប** | | **៧៥.២៨៦.៥៤១** | **៣០៦.៧១៧.៣៦៩** | ៤២.៥១៩.៨៦៦ | ១៧១.៩៩២.៨៥៨ |

# របាយការណ៍ចំណូលលម្អិត

| | កំណត់សម្គាល់ | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣.១)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.១) |
| ចំណូលការប្រាក់ | ១៥ | **៨.៨៩៨.៧៦៥** | **៣៦.២០០.១៧៦** | ៤.៧៦៦.៥៨៨ | ១៩.៤៣៨.១៤៦ |
| ចំណាយការប្រាក់ | ១៣ | **(១.៣៧១.៣០២)** | **(៥.៥៧៨.៤៥៧)** | (៨៤០.០៣៩) | (៣.៤២៥.៦៧៩) |
| **ចំណូលការប្រាក់សុទ្ធ** | | **៧.៥២៧.៤៦៣** | **៣០.៦២១.៧១៩** | ៣.៩២៦.៥៤៩ | ១៦.០១២.៤៦៧ |
| ចំណូលផ្សេងៗ | ១៦ | **៤៥៣.៣៩៦** | **១.៨៤៤.៤១៥** | ៤១៩.៦៧៥ | ១.៧១១.៤៣៥ |
| **ចំណូលប្រតិបត្តិការ** | | **៧.៩៨០.៨៥៩** | **៣២.៤៦៦.១៣៤** | ៤.៣៤៦.២២៤ | ១៧.៧២៣.៩០២ |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ១៧ | **(៤.៤៥៥.៧៩៨)** | **(១៨.១២៦.១៨៦)** | (២.៨៧៤.៧៩៧) | (១១.៧២៣.៤២២) |
| សំវិធានធនលើសមតុល្យជាមួយធនាគារផ្សេងៗ | ៥.២ | **(១៧.៧៦៧)** | **(៧២.២៧៦)** | ១៧.៥៥៤ | ៧១.៥៨៥ |
| សំវិធានធនលើឥណទានអាក្រក់ និង ជាប់សង្ស័យ | ៧ | **(៤៧២.៣៤៧)** | **(១.៩២១.៥០៨)** | (២៩៣.៥៤៦) | (១.១៩៧.០៨១) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | | **៣.០៣៤.៩៤៧** | **១២.៣៤៦.១៦៤** | ១.១៩៥.៤៣៥ | ៤.៨៧៤.៩៨៤ |
| ចំណាយពន្ធលើប្រាក់ចំណូល | ១៨.១ | **(៧២៨.៦០៦)** | **(២.៩៦៣.៩៦៩)** | (៣៦២.៦៥៨) | (១.៤៧៨.៩១៩) |
| **ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ** | | **២.៣០៦.៣៤១** | **៩.៣៨២.១៩៥** | ៨៣២.៧៧៧ | ៣.៣៩៦.០៦៥ |
| **ចំណូលលម្អិតផ្សេងៗ -** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **៤៥៣.៦២៩** | - | (៤៥៧.៤៥៣) |
| **ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | | **២.៣០៦.៣៤១** | **៩.៨៣៥.៨២៤** | ៨៣២.៧៧៧ | ២.៩៣៨.៦១២ |

# របាយការណ៍បម្រែបម្រួលមូលធន

| | កំណត់ | ដើមទុន | | ចំណេញរក្សាទុក | | ប្រាក់បម្រុងតាមបទបញ្ញត្តិ | | លម្អៀងពីការប្តូររូបិយប័ណ្ណបង្ករ | មូលធនសរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (កំណត់សម្គាល់៣.១) | | (កំណត់សម្គាល់៣.១) | | (កំណត់សម្គាល់៣.១) | (កំណត់សម្គាល់៣.១) | | កំណត់សម្គាល់(៣.១) |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | **១១** | **១៥.០០០.០០០** | **៦០.២៧០.០០០** | **១៣.២៦៣** | **២១២.៣៨៦** | **១៥១.៨៩០** | **៦១៤.៩៣០** | **២៤៥.៧៥៨** | **១៥.១៦៥.១៥៣**<br>**១៥.១៦៥.១៥៣** | **៦១.៣៤៣.០៤៤** |
| **ចំណេញក្នុងការិយបរិច្ឆេទ** | | **-** | **-** | **២.៣០៦.៣៤១** | **៩.៣៨២.១៩៥** | **-** | **-** | | **២.៣០៦.៣៤១** | **៩.៣៨២.១៩៥** |
| **ភាពលើសនៃតម្រូវការសំវិធានធនឥណទានតាមគោលការណ៍ធនាគារជាតិនៃកម្ពុជាសម្រាប់ CIFRS for SME** | **១២** | **-** | **-** | **(៣៨.៧២៨)** | **(១៥៧.៥៤៦)** | **(៣៨.៧២៨)** | **(១៥៧.៥៤៦)** | **-** | **-** | **-** |
| **លម្អៀងពីការប្តូររូបិយប័ណ្ណ** | | **-** | **-** | **-** | **-** | **-** | **-** | **៤៥៣.៦២៩** | **-** | **៤៥៣.៦២៩** |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **១១** | **១៥.០០០.០០០** | **៦០.២៧០.០០០** | **២.២៨០.៨៧៦** | **៩.៤៣៧.០០៥** | **១៩០.៦១៨** | **៧៧២.៤៧៦** | **៦៩៩.៣៨៧** | **១៧.៤៧១.៤៩៤** | **៧១.១៧៨.៨៦៨** |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ១១ | ១៥.០០០.០០០ | ៦០.២៧០.០០០ | (៨១៥.០៤៣) | (៣.១៦៥.៤៧៦) | ១៤៧.៤១៩ | ៥៩៦.៦៩៧ | ៧០៣.២១១ | ១៤.៣៣២.៣៧៦ | ៥៨.៤០៤.៤៣២ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | ៨៣២.៧៧៧ | ៣.៣៩៦.០៦៥ | - | - | - | ៨៣២.៧៧៧ | ៣.៣៩៦.០៦៥ |
| ភាពលើសនៃតម្រូវការសំវិធានធនឥណទានតាមគោលការណ៍ធនាគារជាតិនៃកម្ពុជាសម្រាប់ CIFRS for SME | ១២ | - | - | (៤.៤៧១) | (១៨.២៣៣) | ៤.៤៧១ | ១៨.២៣៣ | - | - | - |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | (៤៥៧.៤៥៣) | - | (៤៥៧.៤៥៣) |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ១១ | ១៥.០០០.០០០ | ៦០.២៧០.០០០ | ១៣.២៦៣ | ២១២.៣៨៦ | ១៥១.៨៩០ | ៦១៤.៩៣០ | ២៤៥.៧៥៨ | ១៥.១៦៥.១៥៣ | ៦១.៣៤៣.០៤៤ |

# របាយការណ៍លំហូរសាច់ប្រាក់

| | កំណត់សម្គាល់ | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ពាន់រៀល (កំណត់សម្គាល់ ៣.១) | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដុល្លារអាមេរិក | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ពាន់រៀល (កំណត់សម្គាល់ ៣.១) |
|---|---|---|---|---|---|
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | **៣.០៣៤.៩៤៧** | **១២.៣៤៦.១៦៤** | ១.១៩៥.៤៣៥ | ៤.៨៧៤.៩៨៤ |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់ | ៩ | **២៤៨.៤៦៩** | **១.០១០.៧៧២** | ១៩០.៦៨៤ | ៧៧៧.៦០៩ |
| រំលស់ទ្រព្យសកម្មអរូបី | ១០ | **១៣.៤៦៦** | **៥៤.៧៨០** | ៩៧៦ | ៣.៩៨០ |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | ៧ | **៤៧២.៣៤៧** | **១.៩២១.៥០៨** | ២៩៣.៥៤៦ | ១.១៩៧.០៨១ |
| សំវិធានធនលើសមតុល្យជាមួយធនាគារផ្សេងៗ | ៥.២ | **១៧.៧៦៧** | **៧២.២៧៦** | (១៧.៤៨៤) | (៧១.៣០០) |
| ចំណាយការប្រាក់ | | **១.៣៧១.៣០២** | **៥.៥៧៨.៤៥៧** | ៧៦៦.៥៧៨ | ៣.១២៦.១០៥ |
| ចំណូលការប្រាក់ | ១៥ | **(៨.៨៩៨.៧៦៥)** | **(៣៦.២០០.១៧៦)** | (៤.៧៦៦.៥៨៨) | (១៩.៤៣៨.១៤៦) |
| ខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១៧ | **៧២៥** | **២.៩៤៩** | ៣៦០ | ១.៤៦៨ |
| **ខាតប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **(៣.៧៣៩.៧៤២)** | **(១៥.២១៣.២៧០)** | (២.៣៣៦.៤៩៣) | (៩.៥២៨.២១៩) |
| បម្រែបម្រួលទុនបង្វិលសុទ្ធ | | | | | |
| បម្រែបម្រួលក្នុង៖ | | | | | |
| ឥណទានផ្តល់ដល់អតិថិជន | | **(២៨.៧៩៦.១៦២)** | **(១១៧.១៤២.៧៨៧)** | (១៧.៨៣៣.៣៩៧) | (៧២.៧២៤.៥៩៣) |
| ទ្រព្យសកម្មផ្សេងៗ | | **(១.២៦០.១០០)** | **(៥.១២៦.០៨៧)** | (៧០.៩៥២) | (២៨៩.៣៤២) |
| គណនីត្រូវសងផ្សេងៗ | | **២០២.០៧២** | **៨២២.០២៩** | ៧៦.២៩៣ | ៣១១.១២៣ |
| **លំហូរសាច់ប្រាក់បានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | **(៣៣.៥៩០.៤៣២)** | **(១៣៦.៦៤៥.៨៧៧)** | (២០.១៦៤.៥៤៩) | (៨២.២៣១.០៣១) |
| ការប្រាក់ដែលបានទទួល | | **៨.០៣៧.២៥៨** | **៣២.៦៩៥.៥៦៦** | ៤.៦៥២.០២៦ | ១៨.៩៧០.៩៦២ |
| ពន្ធលើប្រាក់ចំណូលដែលទូទាត់ | ១៣.២ | **(៤០០.២៥៧)** | **(១.៦២៨.២៤៥)** | (៥៣.១៧៤) | (២១៦.៨៤៤) |
| **លំហូរសាច់ប្រាក់សុទ្ធក្នុងសកម្មភាពប្រតិបត្តិការ** | | **(២៥.៩៥៥.០៦៩)** | **(១០៥.៥៨៥.២២០)** | (១៥.៥៦៥.៦៩៧) | (៦៣.៤៧៦.៩១៣) |
| | | | | | |
| **សកម្មភាពវិនិយោគ** | | | | | |
| ទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | **(៤៧០.៨៩៧)** | **(១.៩១៥.៦០៩)** | (២៥៦.០០៤) | (១.០៤៣.៩៨៤) |
| ទិញទ្រព្យសកម្មអរូបី | ១០ | **(១៨៦.០៣១)** | **(៧៥៦.៧៧៤)** | - | - |
| ចំណូលពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | **២៧៣** | **១.១១១** | ១២០ | ៤៨៩ |
| **លំហូរសាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | **(៦៥៦.៦៥៥)** | **(២.៦៧១.២៧២)** | (២៥៥.៨៨៤) | (១.០៤៣.៤៩៥) |
| | | | | | |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ចំណូលពីប្រាក់កម្ចី | ១៣ | **៤២.៨៤៦.៣២៦** | **១៧៤.២៩៨.៨៥៤** | ១៤.៩០៦.៦០២ | ៦០.៧៨៩.១២៣ |
| ការទូទាត់ប្រាក់កម្ចី | | **(១៣.០០០.០០០)** | **(៥២.៨៨៤.០០០)** | - | - |
| ការទូទាត់ការប្រាក់លើប្រាក់កម្ចី | | **(១.៣៧១.៣០២)** | **(៥.៥៧៨.៤៥៧)** | (៧៦៦.៥៧៨) | (៣.១២៦.១០៥) |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន** | | **២៨.៤៧៥.០២៤** | **១១៥.៨៣៦.៣៩៧** | ១៤.១៤០.០២៤ | ៥៧.៦៦៣.០១៨ |
| | | | | | |
| **បម្រែបម្រួលសាច់ប្រាក់សុទ្ធ៖** | | **១.៨៦៣.៣០០** | **៧.៥៧៩.៩០៥** | (១.៦៨១.៥៥៧) | (៦.៨៥៧.៣៩០) |
| សាច់ប្រាក់ដើមការិយបរិច្ឆេទ | ៥.១ | **១.១៥៣.០១៥** | **៤.៦៦៣.៩៤៧** | ២.៨៣៤.៥៧២ | ១១.៥៥០.៨៨១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **៤៤.៦១៥** | - | (២៩.៥៤៤) |
| **សាច់ប្រាក់ចុងការិយបរិច្ឆេទ** | **៥.១** | **៣.០១៦.៣១៥** | **១២.២៨៨.៤៦៧** | ១.១៥៣.០១៥ | ៤.៦៦៣.៩៤៧ |

BNK BNKC (Cambodia) MFI Plc.

(855) 23 213 900
https://www.bnkcmfi.com/
hq.bnkcc@c.bnkcapital.net
BNKC Cambodia MFI Plc.